STATE OF WASHINGTON
DEPARTMENT OF SOCIAL AND HEALTH SERVICES

លេខអតិថិជន ៖

សូមជម្រាបមកដល់ ______________________________ ៖

យើងសូមផ្តល់ជាអនុសាសន៍ថា អ្នកគួរទាក់ទងទីភ្នាក់ងារមួយក្នុងចំណោមទីភ្នាក់ងារដែលមានឈ្មោះលើបញ្ជីដែលបានភ្ជាប់មកជាមួយនេះ ដើម្បីសម្រេចមើលបើអ្នក អាចនឹងចូលសញ្ជាតិបាន ។

បន្ទាប់ពីបានរស់នៅប្រាំ (5) ឆ្នាំក្នុងឋានៈជាអ្នកតាំងលំនៅអចិន្ត្រៃយ៍ស្របច្បាប់លើទឹកដីសហរដ្ឋ, អ្នកអាចមានលទ្ធភាពសុំចូលសញ្ជាតិអាមេរិកាំងបាន ។ ទីភ្នាក់ងារនេះនឹងជួយអ្នក ដើម្បីសម្រេចចិត្តមើល ថាតើការក្លាយជាពលរដ្ឋអាមេរិកាំងម្នាក់គឺជាការលត្រឹមត្រូវសម្រាប់អ្នកឬយ៉ាងណា ។

អ្នកមិនចាំបាច់ត្រូវតែក្លាយខ្លួនជាពលរដ្ឋអាមេរិកាំងទេ ក៏ប៉ុន្តែបើអ្នកជាពលរដ្ឋអាមេរិកាំង នោះអ្នកអាច ៖

- បោះឆ្នោត
- សុំជំនួយសហព័ន្ធ
- នៅតែទទួលជំនួយ SSI បានក្រោយពីរយៈពេល 7 ឆ្នាំ

ទីភ្នាក់ងារនេះផ្តល់សេវាជូនអ្នកដោយឥតគិតថ្លៃ ។ ពួកគេអាច ៖

- ជួយអ្នកក្នុងការសម្រេចចិត្ត បើការចូលសញ្ជាតិជាការលត្រឹមត្រូវសម្រាប់អ្នក
- ជួយអ្នកក្នុងការត្រៀមខ្លួនធ្វើតេស្តចូលសញ្ជាតិ
- បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់, ជួយអ្នកក្នុងការដាក់ពាក្យសុំការអនុគ្រោះផែកពិការភាព ដើម្បីលើកលែងរូបអ្នកឲ្យរួចផុតពីការធ្វើតេស្ត
- នៅក្នុងករណីភាគច្រើន, ជួយបង់ថ្លៃឈ្នួលសម្រាប់ការដាក់ពាក្យសុំជូនអ្នកទៀតផង

យើងបានផ្ញើបញ្ជីឈ្មោះនៃទីភ្នាក់ងារដែលមានបម្រើការទាំងប៉ុន្មានមកជាមួយសំបុត្រនេះ ។ សូមអញ្ជើញទាក់ទងទីភ្នាក់ងារមួយក្នុងចំណោមទីភ្នាក់ងារនានាទាំងឡាយនោះ ដើម្បីនិយាយជាមួយពួកគេអំពីនីតិវិធីនៃការធ្វើជាតួបនីយកម្ម ។

សូមយកសំបុត្រនេះទៅជួបបុគ្គលិកនៃទីភ្នាក់ងារក្នុងពេលណាត់ជួប ។ ទីភ្នាក់ងារនឹងសុំរក្សាទុកសំណៅចម្លងមួយច្បាប់ ហើយគេនឹងប្រាប់ទៅបុគ្គលិកធ្វើការផែកសង្គមកិច្ចរបស់អ្នកឲ្យបានដឹង ថាតើអ្នកអាចចាប់ផ្តើមដំណើរការដាក់ពាក្យសុំឬយ៉ាងណា, ឬមានរឿងរ៉ាវនានាដែលត្រូវដោះស្រាយ, ឬបានសម្រេចចិត្តថាមិនស្វែងរកការសុំចូលសញ្ជាតិនៅពេលនេះទេ និងមូលហេតុអ្វី ។

ដោយសេចក្តីស្មោះត្រង់,

លេខទូរស័ព្ទ ៖